ក  N°64/16→31/8/2016

# មាតិកា

## I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម


០៩-០៨-២០១៦ -ព្រះរាជក្រម នស/រកម/០៨១៦/០១៣ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស ៧៤៨៩


### ២-ព្រះរាជក្រឹត្យ


២២-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៨១ ស្តីពី ការតែងតាំងលោកជំទាវ **វត្ត ម៉ានី** បច្ចុប្បន្នជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី ឱ្យទទួលភារកិច្ចបន្ថែម ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យ ទីម័រឡេស្តេ ដោយមាននិវេសនដ្ឋាននៅទីក្រុងគូឡាឡាំពួរ នៃប្រទេសម៉ាឡេស៊ី ៧៥០១

២២-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៨២ ស្តីពី ការតែងតាំងឯកឧត្តម **ស្វាន ម៉ាណាន** បច្ចុប្បន្នជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋអារ៉ាប់អេហ្ស៊ីប ឱ្យទទួលភារកិច្ចបន្ថែម ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំរដ្ឋអ៊ីស្រាអែល ដោយមាននិវេសនដ្ឋាននៅទីក្រុងគែរ នៃសាធារណរដ្ឋអារ៉ាប់អេហ្ស៊ីប ៧៥០២

២២-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៨៣ ស្តីពី ការតែងតាំងឯកឧត្តម **សុខ គង់** ជាទីប្រឹក្សារាជរដ្ឋាភិបាល ឋានៈស្មើ រដ្ឋលេខាធិការ ៧៥០៣

២២-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៨៤ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **ខួន សុវណ្ណា** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ៧៥០៤

២២-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៨៥ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **សុខ មនោរម្យ** ជាទីប្រឹក្សាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៧៥០៥

២២-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៨៦ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **សុខ ស៊ីរី** ជាទីប្រឹក្សាក្រសួងពាណិជ្ជកម្ម មានឋានៈស្មើ អគ្គនាយក ៧៥០៦

២២-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៨៧ ស្តីពី ការតែងតាំង និងផ្តល់ឋានៈដល់ឯកឧត្តម **គង់ ទឡ្ហនា** ជាសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយក ៧៥០៧

២២-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៨៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាករណីពិសេស ដល់ឯកឧត្តម **ប្រាក់ ចាន់រឿន** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងរ៉ែ និងថាមពល ៧៥០៨

២២-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៨៩ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ៧៥០៩

២២-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៩០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយទាហានថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ៦៩ រូប ៧៥១០

២២-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៩១ ស្តីពី ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិដល់មន្ត្រីរាជការ ២៧ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងមុខងារសាធារណៈ ៧៥១៣

២២-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៩២ ស្តីពី ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិដល់មន្ត្រីរាជការ ២២ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងមុខងារសាធារណៈ ៧៥១៥

២២-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៩៣ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌដល់មន្ត្រីរាជការ ៧៣ រូប ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងទេសចរណ៍ ៧៥១៧

## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ

៣០-៨-២០១៦ -អនុក្រឹត្យលេខ ១៨០ អនក្រ.បក ស្តីពី ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងក្រុងសៀមរាប និងស្រុកប្រាសាទបាគង ដោយកាត់យកសង្កាត់អំពិល នៃក្រុងសៀមរាប ទៅឱ្យស្រុកប្រាសាទបាគង នៃខេត្តសៀមរាប ៧៥២១

| | | |
|---|---|---|
| ៣០-៨-២០១៦ | -អនុក្រឹត្យលេខ ១៨១ អនក្រ.បក ស្តីពី ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ | ៧៥២៤ |
| ២៦-៨-២០១៦ | -អនុក្រឹត្យលេខ ៩០៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ៧៥៩៧ |
| ២៦-៨-២០១៦ | -អនុក្រឹត្យលេខ ៩០៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៧៥៩៨ |


## III~ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ១១-៨-២០១៦ | -ប្រកាសលេខ ៩៣២ សហវ.ប្រក ស្តីពី ការបង្កើតក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | ៧៦០០ |
| ១៧-៨-២០១៦ | -ប្រកាសលេខ ០០៥/១៦ គ.ម.ក./ប្រក ស្តីពី វិនិយោគិនគុណវុឌ្ឍិក្នុងវិស័យមូលបត្រ | ៧៦០៤ |

# ព្រះរាជក្រម

នស/រកម/០៨១៦/០១៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោធិភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

## ស្តីពី

# ការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងតម្លាភាពក្នុងការព្យាបាលសង្គ្រោះជីវិត និងបង្កើនសុខុមាលភាពរបស់ប្រជាពលរដ្ឋតាមរយៈការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស និងធានាការពារទប់ស្កាត់ការជួញដូរកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីក្នុងការគ្រប់គ្រងការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្សប្រកបដោយសុវត្ថិភាព និងស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពដែលពាក់ព័ន្ធនឹងអ្នកបរិច្ចាគមានជីវិត ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស ។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចតទៅ ៖

- **មន្ទីរពេទ្យ** សំដៅដល់មន្ទីរពេទ្យសាធារណៈ និងឯកជន ដែលបានចុះបញ្ជី និងប្រកាសទទួលស្គាល់ដោយក្រសួងសុខាភិបាលជាមន្ទីរពេទ្យដែលមានគុណវុឌ្ឍិក្នុងការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស ។
- **អ្នកប្រកបវិជ្ជាជីវៈ** សំដៅដល់អ្នកមានវិជ្ជាជីវៈទាំងឡាយណាដែលបានចុះបញ្ជីក្នុងគណៈវិជ្ជាជីវៈសុខាភិបាល និងគណៈវិជ្ជាជីវៈពាក់ព័ន្ធ និងមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈត្រឹមត្រូវ ។
- **កោសិកា** សំដៅដល់ឯកតាដ៏តូចបំផុតនៃសារពាង្គកាយរស់ ដែលអាចយកទៅផ្សាំ ហើយអាចបំពេញមុខងារបាន ។
- **ជាលិកា** សំដៅដល់បណ្តុំនៃកោសិកាជាច្រើន ហើយបណ្តុំនៃជាលិកានេះបង្កើតជាផ្នែកណាមួយនៃសារពាង្គកាយរស់ ។
- **សរីរាង្គ** សំដៅដល់ផ្នែកទាំងមូល ឬបំណែកសំខាន់ណាមួយនៃសារពាង្គកាយមនុស្ស ដែលកើតចេញមកពីបណ្តុំជាលិកា និងបណ្តាញសរសៃឈាមស្រោចស្រព ហើយអាចបំពេញមុខងារសរីរសាស្ត្រ ក្នុងកម្រិតស្វយ័តណាមួយ ។

- **ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស** សំដៅដល់ដំណើរការនៃការដកយក ការដាក់ចូល ការរក្សាទុក ការដឹកជញ្ជូន ការផ្ទេរផ្គងកោសិកា ជាលិកា ឬសរីរាង្គមនុស្ស តាមលក្ខណៈបច្ចេកទេសវេជ្ជសាស្ត្រត្រឹមត្រូវ ។
- **ការធ្វើពាណិជ្ជកម្ម** សំដៅដល់ទម្រង់នៃការជួញដូរកោសិកា ជាលិកា ឬសរីរាង្គមនុស្សដើម្បីកេងចំណេញផលប្រយោជន៍ផ្ទាល់ខ្លួន ។

## ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រង

### មាត្រា ៥.-

ក្រសួងសុខាភិបាល ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងផ្តល់ការអនុញ្ញាតដល់មន្ទីរពេទ្យ និងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាលក្នុងការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ។

ក្រសួងសុខាភិបាលត្រូវបង្កើតគណៈកម្មាធិការមួយដើម្បីគ្រប់គ្រង ត្រួតពិនិត្យ និងអនុញ្ញាតដល់មន្ទីរពេទ្យ និងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាលក្នុងការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ជំពូកទី ៣
## ការបរិច្ចាគ និងការទទួលសរីរាង្គមនុស្ស
## ផ្នែកទី ១
## គោលការណ៍ទូទៅ

### មាត្រា ៦.-

ការបរិច្ចាគ និងការទទួលសរីរាង្គមនុស្សត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម ៖

- តាមការស្ម័គ្រចិត្តពីអ្នកបរិច្ចាគ និងអ្នកទទួល ឬគោលបំណងសប្បុរសធម៌ និងមនុស្សធម៌
- មិនធ្វើពាណិជ្ជកម្ម និងមិនមានការផ្សាយពាណិជ្ជកម្ម
- សុវត្ថិភាពសុខភាពរបស់អ្នកបរិច្ចាគ និងអ្នកទទួល និង

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

- រក្សាការសម្ងាត់របស់អ្នកបរិច្ចាគ និងអ្នកទទួល លើកលែងតែមានការឯកភាពគ្នាពីភាគីពាក់ព័ន្ធ ឬកំណត់ដោយច្បាប់ជាធរមាន ។

## ផ្នែកទី ២
## អ្នកបរិច្ចាគ

**មាត្រា ៧.-**

អ្នកបរិច្ចាគ ត្រូវមានអាយុយ៉ាងតិច ១៨ ឆ្នាំ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ហើយវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ។

ចំពោះជនវិកលចរិត ឬជនវិបល្លាសស្មារតី ការបរិច្ចាគកោសិកា ជាលិកា និងសរីរាង្គត្រូវហាមឃាត់ ទោះជាមានការយល់ព្រមពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលក៏ដោយ ។

**មាត្រា ៨.-**

អ្នកបរិច្ចាគមានសិទ្ធិ ឬអនុញ្ញាតឲ្យមានការដកចេញនូវកោសិកា ជាលិកា និងសរីរាង្គណាមួយរបស់ខ្លួនតាមរយៈការបរិច្ចាគដោយស្ម័គ្រចិត្តក្នុងគោលបំណងព្យាបាលជំងឺ និងមិនធ្វើពាណិជ្ជកម្ម ។

**មាត្រា ៩.-**

អ្នកបរិច្ចាគ និងអ្នកទទួលត្រូវព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរ ការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរត្រូវធ្វើនៅចំពោះមុខគណៈកម្មការសម្រាប់ផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ។ ប្រសិនបើអ្នកបរិច្ចាគ ឬអ្នកទទួលមិនចេះអក្សរ ការព្រមព្រៀងត្រូវសរសេរឲ្យច្បាស់លាស់ក្នុងកំណត់ហេតុថាអ្នកព្រមព្រៀងមិនចេះអក្សរយល់ព្រមជាមួយគ្នា ដើម្បីឲ្យមន្ទីរពេទ្យធ្វើការវះកាត់ និងផ្លាស់ប្តូរនូវសរីរាង្គរបស់ខ្លួន ។

**មាត្រា ១០.-**

អ្នកបរិច្ចាគត្រូវទទួលបាននូវការថែទាំសុខភាព សុខុមាលភាពមុនពេល ក្នុងកំឡុងពេល និងក្រោយពេលបរិច្ចាគ ពីមន្ទីរពេទ្យដែលធ្វើការផ្សាំកោសិកា ជាលិកា និងសរីរាង្គ ។

រាល់ការចំណាយលើការថែទាំសុខភាព សុខុមាលភាពដែលទាក់ទងនឹងការផ្សាំកោសិកា ជាលិកា និងសរីរាង្គមុនពេល ក្នុងកំឡុងពេល និងក្រោយពេលបរិច្ចាគជាបន្ទុករបស់មន្ទីរពេទ្យដែលធ្វើការផ្សាំកោសិកា ជាលិកា និងសរីរាង្គ ។



## ផ្នែកទី ៣
## អ្នកទទួល

**មាត្រា ១១.-**

អ្នកទទួលដែលរង់ចាំការបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គរបស់បុគ្គលណាម្នាក់ដែលមិនបានព្រមព្រៀងគ្នាជាមុន ត្រូវចុះឈ្មោះក្នុងបញ្ជីរង់ចាំ ។

បែបបទ និងនីតិវិធីបញ្ជីរង់ចាំនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ផ្នែកទី៤
## ករណីយកិច្ចរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល

**មាត្រា ១២.-**

អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលរបស់មន្ទីរពេទ្យ ត្រូវពន្យល់អំពីដំណើរការនៃការបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គមនុស្ស និងរាល់ផលប៉ះពាល់ ឬផលវិបាក ឬគ្រោះថ្នាក់ដែលអាចកើតមានឡើងដល់អ្នកបរិច្ចាគមុននឹងសុំការយល់ព្រម ។

អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលរបស់មន្ទីរពេទ្យ ត្រូវធានាឲ្យបានថាអ្នកដែលផ្តល់ការយល់ព្រមបរិច្ចាគពិតជាបានយល់ និងមានសមត្ថភាពសតិបញ្ញាពេញលេញក្នុងការធ្វើសេចក្តីសម្រេចចិត្តបរិច្ចាគ ។

**មាត្រា ១៣.-**

អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ដែលបានអនុញ្ញាតដោយក្រសួងសុខាភិបាលឲ្យធ្វើការងារទាក់ទងនឹងការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្សត្រូវពន្យល់អំពីដំណើរការនៃការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស និងរាល់គុណប្រយោជន៍ ផលប៉ះពាល់ ផលវិបាក ឬគ្រោះថ្នាក់ដែលអាចមានទាក់ទងនឹងការផ្សាំ មុននឹងមានការយល់ព្រមពីអ្នកទទួល ។

**មាត្រា ១៤.-**

រាល់ការសុំការយល់ព្រមក្នុងការបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរចំនួន ២ (ពីរ) ច្បាប់ ដែលត្រូវរក្សាទុកនៅមន្ទីរពេទ្យដែលធ្វើការផ្សាំកោសិកា ជាលិកា ឬសរីរាង្គ ១ (មួយ) ច្បាប់ និងក្រសួងសុខាភិបាល ១ (មួយ) ច្បាប់ ។

**មាត្រា ១៥.-**

បន្ទាប់ពីដកកោសិកា ជាលិកា ឬសរីរាង្គមនុស្សចេញពីរាងកាយរបស់មនុស្ស អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលរបស់មន្ទីរពេទ្យត្រូវចាត់វិធានការរក្សាកោសិកា ជាលិកា ឬសរីរាង្គមនុស្សដែលបានដកចេញនោះ ដោយគោរពតាមគោលការណ៍បច្ចេកទេសដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ជំពូកទី ៥
## ករណីយកិច្ចរបស់មន្ទីរពេទ្យ

### មាត្រា ១៦.-

មន្ទីរពេទ្យ ត្រូវទទួលខុសត្រូវរៀបចំបង្កើតគណៈកម្មការសម្រាប់ការងារផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្សដើម្បី ៖

-វាយតម្លៃអំពីសមត្ថភាព និងលទ្ធភាពបរិច្ចាគរបស់អ្នកដែលមានសក្តានុពលក្នុងការបរិច្ចាគ កោសិកា ជាលិកា ឬសរីរាង្គ

- តាមដាន និងឃ្លាំមើលការវិវត្តទៅរកភាពជាសះស្បើយក្រោយពេលវះកាត់ដកកោសិកា ជាលិកា ឬសរីរាង្គរហូតដល់ពេលអ្នកបរិច្ចាគមានស្ថានភាពសុខភាពធម្មតា

- ផ្តល់ការថែទាំ ព្យាបាល និងតាមដានបញ្ហាសុខភាពដែលពាក់ព័ន្ធនឹងការបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គ ។

តួនាទី និងភារកិច្ចរបស់គណៈកម្មការសម្រាប់ការងារផ្សាំកោសិកា ជាលិកា សរីរាង្គនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

### មាត្រា ១៧.-

ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស មិនត្រូវបានអនុញ្ញាតឲ្យធ្វើឡើងក្នុងគោលបំណងធ្វើពាណិជ្ជកម្មឡើយ ។

ការផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្មទាក់ទងទៅនឹងការទិញលក់សរីរាង្គមនុស្ស ត្រូវហាមឃាត់ជាដាច់ខាត ។

## ជំពូកទី ៦
## ករណីយកិច្ចរបស់ក្រសួងសុខាភិបាល

### មាត្រា ១៨.-

ក្រសួងសុខាភិបាលត្រូវធ្វើប្រតិបត្តិការត្រួតពិនិត្យរាល់សកម្មភាពដែលពាក់ព័ន្ធ ទៅលើការផ្សាំកោសិកា ជាលិកា ឬសរីរាង្គ ។

សិទ្ធិ និងតួនាទីភារកិច្ចរបស់ភាគីដែលពាក់ព័ន្ធនឹងការផ្សាំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ១៩.-**

មន្ទីរពេទ្យ និងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាលក្នុងការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ត្រូវសុំការអនុញ្ញាតពីក្រសួងសុខាភិបាល ។

បែបបទ និងលក្ខខណ្ឌនៃការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ជំពូកទី ៤
## ទោសប្បញ្ញត្តិ

**មាត្រា ២០.-**

អំពើប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ក្នុងការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២១.-**

អំពើដកយកកោសិកា ជាលិកា ឬសរីរាង្គមនុស្សពីជនដែលត្រូវបានហាមឃាត់ការបរិច្ចាគ ដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើខាងលើនេះ នាំឲ្យមានការកាត់អវយវៈ ឬនាំឲ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ឬបណ្តាលឲ្យជនរងគ្រោះស្លាប់ដោយគ្មានចេតនាសម្លាប់ ។

**មាត្រា ២២.-**

អំពើដកយកកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ដោយគ្មានការបង្ហាញឆន្ទៈយល់ព្រមបរិច្ចាគពីអ្នកបរិច្ចាគ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដូចកថាខណ្ឌទី ១ ខាងលើ ចំពោះអំពើអូសទាញ លួងលោម បោកបញ្ឆោត ឬប្រើឧបាយកលទុច្ចរិតផ្សេងទៀត ដើម្បីទទួលបានការយល់ព្រមបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គមនុស្សពីអ្នកបរិច្ចាគ ។

ត្រូវចាត់ទុកថាគ្មានការយល់ព្រមពីអ្នកបរិច្ចាគ ចំពោះករណីដែលការព្រមព្រៀងរវាងអ្នកបរិច្ចាគ និងអ្នកទទួល មិនបានធ្វើជាលាយលក្ខណ៍អក្សរ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើខាងលើនេះ នាំឲ្យមានការកាត់អវយវៈ ឬនាំឲ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ឬបណ្តាលឲ្យជនរងគ្រោះស្លាប់ដោយគ្មានចេតនាសម្លាប់ ។

**មាត្រា ២៣.-**

អំពើផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ក្នុងគោលបំណងពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ២៤.-**

អំពើផ្សព្វផ្សាយពាណិជ្ជកម្មទាក់ទងនឹងការទិញលក់សរីរាង្គមនុស្ស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ២៥.-**

អំពើបំពានកាតព្វកិច្ចដូចបានកំណត់ក្នុងមាត្រា ១០ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន)រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ២៦.-**

អំពើមិនផ្តល់ព័ត៌មានអំពីដំណើរការនៃការបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គមនុស្ស និងផលប៉ះពាល់ ឬផលវិបាក ឬគ្រោះថ្នាក់ដែលអាចកើតមានឡើងដល់អ្នកបរិច្ចាគ មុននឹងសុំការយល់ព្រម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

**មាត្រា ២៧.-**

អំពើមិនផ្តល់ព័ត៌មានអំពីដំណើរការនៃការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស និងរាល់គុណប្រយោជន៍ ផលប៉ះពាល់ ផលវិបាក ឬគ្រោះថ្នាក់ ដែលអាចកើតមានដល់អ្នកទទួល មុននឹងមានការយល់ព្រមពីអ្នកទទួល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

**មាត្រា ២៨.-**

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចមានចែងក្នុងមាត្រា ២០៦ (ទោសបន្ថែម : ប្រភេទ និងរយៈពេល) នៃក្រមព្រហ្មទណ្ឌ អាចត្រូវបានប្រកាសចំពោះរូបវន្តបុគ្គល ។

**មាត្រា ២៩.-**

ចំពោះបទមជ្ឈិមដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចមានចែងក្នុងមាត្រា ២០៨ (ទោសបន្ថែម : ប្រភេទ និងរយៈពេល) នៃក្រមព្រហ្មទណ្ឌ អាចត្រូវបានប្រកាសចំពោះរូបវន្តបុគ្គល ។

**មាត្រា ៣០.-**

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៤ នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ ៖

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

២-ការដាក់ឲ្យស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការតាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ ។

៤-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមព្រហ្មទណ្ឌ ។

៥-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមព្រហ្មទណ្ឌ ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ៣១.-**

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២០ មាត្រា ២៥ មាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ ៖

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

២-ការដាក់ឲ្យស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ ។

៤-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមព្រហ្មទណ្ឌ ។

៥-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមព្រហ្មទណ្ឌ ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ ។

## ជំពូកទី ៥
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ៣២.-**

ការគ្រប់គ្រងឈាម មេជីវិត ខួរឆ្អឹង និងកោសិកាដើមរបស់មនុស្ស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ៣៣.-**

បទប្បញ្ញត្តិទាក់ទងនឹងការនាំចេញកោសិកា ជាលិកា សរីរាង្គមនុស្ស ទៅក្រៅប្រទេស ឬនាំចូលកោសិកា ជាលិកា សរីរាង្គមនុស្ស មកក្នុងប្រទេសកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ៣៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

នស.រកម.០៨១៦.០១៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ហត្ថលេខា**

**ម៉ម ប៊ុនហេង**

លេខ: ៧៥៤.ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៦/៧៨១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងលោកជំទាវ **រត្ន ម៉ានី** បច្ចុប្បន្នជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី **ឲ្យទទួលភារកិច្ចបន្ថែម** ជា **ឯកអគ្គរាជទូត**វិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យ **ទីម័រឡេស្តេ** ដោយមាននិវេសនដ្ឋាននៅទីក្រុង**គូឡាឡាំពួរ** នៃប្រទេសម៉ាឡេស៊ី។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរ.១៦០៧.៧៩៤

លេខៈ ៦៧៩ ៤ ស.ណ

សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៦*

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៦/ ៧៨២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង ឯកឧត្តម **ស្វាន ម៉ាណាន** បច្ចុប្បន្នជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋអារ៉ាប់អេហ្ស៊ីប **ឲ្យទទួលភារកិច្ចបន្ថែមជា ឯកអគ្គរាជទូត** វិសាមញ្ញនិងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជាប្រចាំរដ្ឋ **អ៊ីស្រាអែល** ដោយមាននិវេសនដ្ឋាន នៅទីក្រុងគែរ នៃសាធារណរដ្ឋអារ៉ាប់អេហ្ស៊ីប ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣.រ.ស. ១៦០៨.៧៩៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦*

លេខ: ៧៩៣ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៦/៧៨៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង ឯកឧត្តម **សុខ គន់** ជាទីប្រឹក្សារាជរដ្ឋាភិបាល ឋានៈស្មើ រដ្ឋលេខាធិការ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៦០៨. ៧៩៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦*

លេខ: ៧៩៨ ស.ណ
**សំណៅដែលមានតម្លៃជាការចេញផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៦/៧៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំង និងផ្តល់ឋានៈឯកឧត្តម **ខួន សុវណ្ណា** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១៦០៨. ៧៩៧

លេខ: ៧៩២ស.ណ
សំណៅចែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៦/៧៨៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តែងតាំង និងផ្តល់ឋានៈឯកឧត្តម **សុខ មនោរម្យ** ជាទីប្រឹក្សាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៧៩១ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

ពរល. ១៦០៨. ៧៩៨

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៦/៧៩៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមាន ឋានៈស្មើ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង និងផ្តល់ឋានៈឯកឧត្តម **សុខ សិរី** ជាទីប្រឹក្សាក្រសួងពាណិជ្ជកម្ម មានឋានៈស្មើអគ្គនាយក ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១៦០៧. ៧៩៩

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦*

លេខៈ៤០០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៦/៧៨៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង និងផ្តល់ឋានៈដល់ឯកឧត្តម **គង់ ចន្ថុនា** ជាសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៧៩៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

ការ. ១៦០៧. ៨០០

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦*

នស/រកត/០៨១៦/៧៨៩

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិជាករណីពិសេស ដល់ឯកឧត្តម **ប្រាក់ ចាន់រឿន** ពីឋានន្តរស័ក្តិវរមន្ត្រីថ្នាក់លេខ ២ មកឋានន្តរស័ក្តិឧត្តមមន្ត្រីថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងរ៉ែ និងថាមពល។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខៈ ៧៩៧ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣៤៧.១៦០៨.៨០១

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦*

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៦/៧៨៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោរាគាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ឯក** ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- ឧត្តមសេនីយ៍ទោ **ម៉ិញ សុធីវណ្ណា** អត្តលេខ ០៧០២

២- ឧត្តមសេនីយ៍ទោ **អ៊ុក វណ្ណា** អត្តលេខ ០១០០៦

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៧៩៥ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣១៧.១៦០៧.៩០៤

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦*

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៦/៧៩០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ ដល់ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក**

| | | | |
|---|---|---|---|
| -ឧត្តមសេនីយ៍ទោ | **សរ** | **ស៊ីនឿន** | អត្តលេខ ០០០៩២១ |

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី | **គង់** | **សារ៉ាន់** | អត្តលេខ ០០៣២៤១ |
| ២-ឧត្តមសេនីយ៍ត្រី | **សុខ** | **សាវ៉ាត** | អត្តលេខ ០០៣៨៧៧ |

**គ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | **អ៊ុំ** | **ណារ្ម៉ី** | អត្តលេខ ០១២២៦៨ |
| ២-វរសេនីយ៍ឯក | **ពុំ** | **ចាន់ថា** | អត្តលេខ ០១៧២៦៦ |
| ៣-វរសេនីយ៍ឯក | **សេង** | **ពិទូរ្យ** | អត្តលេខ ២១៨៧០៧ |
| ៤-វរសេនីយ៍ឯក | **ជាវ** | **ហុងសេង** | អត្តលេខ ០០១៨៥៦ |
| ៥-វរសេនីយ៍ឯក | **តាល់** | **សុខា** | អត្តលេខ ០០៥១៥៣ |
| ៦-វរសេនីយ៍ឯក | **សេក** | **វណ្ណារី** | អត្តលេខ ០១២៥១១ |
| ៧-វរសេនីយ៍ឯក | **និត** | **សាន** | អត្តលេខ ០០៣៤៨៤ |
| ៨-វរសេនីយ៍ឯក | **ណុប** | **សុវណ្ណមុលី** | អត្តលេខ ០០៣៤៧២ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៩-វរសេនីយ៍ឯក ថាច់ ច័ន្ទតារា អត្តលេខ ០០០៦៦២
១០-វរសេនីយ៍ឯក សខ សុផល អត្តលេខ ០០១៩០២
១១-វរសេនីយ៍ឯក ហេង សាម៉ាច អត្តលេខ ០០១៩២៦
១២-វរសេនីយ៍ឯក ប្រាក់ ហឿន អត្តលេខ ០០៥៥៦៨
១៣-វរសេនីយ៍ឯក ឆែ ស៊ីដា អត្តលេខ ០២៥៧៧៤
១៤-វរសេនីយ៍ឯក ឡុក លី អត្តលេខ ០០៤១៣៥
១៥-វរសេនីយ៍ឯក សំរិទ្ធ សារិទ្ធ អត្តលេខ ០២៧០៣២
១៦-វរសេនីយ៍ឯក ឡុក សេង អត្តលេខ ០១៦៦៤១
១៧-វរសេនីយ៍ឯក អ៊ុក សុភា អត្តលេខ ០២៦៤៦១
១៨-វរសេនីយ៍ឯក ប្រាក់ សារុន អត្តលេខ ០០២១៨២
១៩-វរសេនីយ៍ឯក ទេព តីរម្សៀ អត្តលេខ ០១៦៦២២
២០-វរសេនីយ៍ឯក ខឹម បូណា អត្តលេខ ០៣៤០៣០
២១-វរសេនីយ៍ឯក ហុង ហ៊ាន អត្តលេខ ០៣៤០៣២
២២-វរសេនីយ៍ឯក ម៉ែន យ៉ន អត្តលេខ ០០៩៣៥៤
២៣-វរសេនីយ៍ឯក ផង់ តារាវណ្ណា អត្តលេខ ០០០៦៤២
២៤-វរសេនីយ៍ឯក ជីវ ស៊ីវហេង អត្តលេខ ០២៥៨៥១
២៥-វរសេនីយ៍ឯក ប៉ាន់ ប៊ុនថន អត្តលេខ ០០០២៨៥
២៦-វរសេនីយ៍ឯក ទេព ចន្ធី អត្តលេខ ០០២០៤៦
២៧-វរសេនីយ៍ឯក កើត សុវណ្ណារិទ្ធ អត្តលេខ ០០៤០៨៣
២៨-វរសេនីយ៍ឯក ហួត សុវណ្ណា អត្តលេខ ០១០១០៧
២៩-វរសេនីយ៍ឯក សុខ សាវ៉ាត អត្តលេខ ០០៣៤៣០
៣០-វរសេនីយ៍ឯក ស្វាយ សឿន អត្តលេខ ០០២០១៨
៣១-វរសេនីយ៍ឯក ផេង ប៊ុនធឿន អត្តលេខ ០២៧៦៧៦
៣២-វរសេនីយ៍ឯក ដួង សុតា អត្តលេខ ០៣៦៦១០
៣៣-វរសេនីយ៍ឯក សៅ ច័ន្ទ អត្តលេខ ០០០៦៤៤
៣៤-វរសេនីយ៍ឯក ឃឹម តារា អត្តលេខ ០៥១៩៩២
៣៥-វរសេនីយ៍ឯក ឡុង វ៉ាន់ អត្តលេខ ០០៣៧៦១
៣៦-វរសេនីយ៍ឯក ប៉ាង ខេមរី អត្តលេខ ០០៤១៤៧
៣៧-វរសេនីយ៍ឯក ហ៊ុយ សារុន អត្តលេខ ០១៦៩៩៦
៣៨-វរសេនីយ៍ឯក កៅ វណ្ណារ៉ែត អត្តលេខ ០១៥៥៣០
៣៩-វរសេនីយ៍ឯក សន ណារុំ អត្តលេខ ០០៨៩៩៨
៤០-វរសេនីយ៍ឯក ទួន ផាន់ណារ៉ែតអត្តលេខ ០០៨៩៩៩
៤១-វរសេនីយ៍ឯក មុំ សារ៉ែត អត្តលេខ ០០៨៩៦៦
៤២-វរសេនីយ៍ឯក សម សុវណ្ណា អត្តលេខ ០០៩០៥៨
៤៣-វរសេនីយ៍ឯក យង់ សុផុន អត្តលេខ ០១៧១០៤
៤៤-វរសេនីយ៍ឯក ខៀវ យ៉ុង អត្តលេខ ០០០៧៧៩
៤៥-វរសេនីយ៍ឯក ភង សំអូន អត្តលេខ ០១០៥៥៩
៤៦-វរសេនីយ៍ឯក នីវ សាវុធ អត្តលេខ ០២៤៤៤៩
៤៧-វរសេនីយ៍ឯក ហេង សុផល អត្តលេខ ០០៩៣៧៦
៤៨-វរសេនីយ៍ឯក អ៊ី សាវឿន អត្តលេខ ០០៣១៥៨
៤៩-វរសេនីយ៍ឯក លី បញ្ញា អត្តលេខ ០១៣០៥៥
៥០-វរសេនីយ៍ឯក សង់ ប៊ុនណាត អត្តលេខ ០១៧១៦៩
៥១-វរសេនីយ៍ឯក កែវ សុផៃ អត្តលេខ ០២១៧៤៥

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ៥២-វរសេនីយ៍ឯក | ស្ងួស | សារុ | អត្តលេខ ០៩៥៥១២ |
| ៥៣-វរសេនីយ៍ឯក | ហ៊ុយ | ឧត្តម | អត្តលេខ ០០១៤៩០ |
| ៥៤-វរសេនីយ៍ឯក | ជុន | ពៅ | អត្តលេខ ០០៩៦៩៩ |
| ៥៥-វរសេនីយ៍ឯក | ស៊ិន | សុវណ្ណារ៉េត | អត្តលេខ ០១៧៨៧៤ |
| ៥៦-វរសេនីយ៍ឯក | ស៊ូ | សម្បត្តិ | អត្តលេខ ០១៧៨៧៨ |
| ៥៧-វរសេនីយ៍ឯក | ជឹម | សារ៉េន | អត្តលេខ ០០១៩៣៥ |
| ៥៨-វរសេនីយ៍ឯក | ចាន់ | សំណាង | អត្តលេខ ០១២០២៦ |
| ៥៩-វរសេនីយ៍ឯក | ម៊ិន | សារី | អត្តលេខ ០១៧៩០៣ |
| ៦០-វរសេនីយ៍ឯក | ជា | គឹមសាយ | អត្តលេខ ០២៧៧០២ |
| ៦១-វរសេនីយ៍ឯក | ទេស | សុឧត្តម | អត្តលេខ ០០២៧១១ |
| ៦២-វរសេនីយ៍ឯក | ល្មៀក | សុខនី | អត្តលេខ ០១០២៣៥ |
| ៦៣-វរសេនីយ៍ឯក | ម៉ិច | ណាង | អត្តលេខ ០០៩៥៨០ |
| ៦៤-វរសេនីយ៍ឯក | ឃួន | ចំរើន | អត្តលេខ ០១៧១៩០ |
| ៦៥-វរសេនីយ៍ឯក | នូ | ឧត្តរី | អត្តលេខ ០០៨៧២៤ |
| ៦៦-វរសេនីយ៍ឯក | ហេង | នីភា | អត្តលេខ ០១៤៦៩០ |

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.០៨១៦.៩០៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៦*

លេខ: ៩០៤ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៦/ ៧៩១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងថ្នាក់ដល់មន្ត្រីរាជការ ២២ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងមុខងារសាធារណៈ ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៦ ៖

១-ឯកឧត្តម **គង់ សុភី** ពីឧត្តមមន្ត្រី ថ្នាក់លេខ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ២
២-ឯកឧត្តម **ឆាយ ឆត្រាឧុង** ពីឧត្តមមន្ត្រី ថ្នាក់លេខ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ២
៣-លោក **ឈុន សុជាតិ** ពីឧត្តមមន្ត្រី ថ្នាក់លេខ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ២
៤-លោក **ស៊ូម សារឿន** ពីឧត្តមមន្ត្រី ថ្នាក់លេខ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ២
៥-លោក **ស៊ិន សុឃន** ពីឧត្តមមន្ត្រី ថ្នាក់លេខ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ២
៦-ឯកឧត្តម **យក់ ប៊ុនណា** ពីឧត្តមមន្ត្រី ថ្នាក់លេខ៤ មកឧត្តមមន្ត្រី ថ្នាក់លេខ៣

| | | |
|---|---|---|
| ៧-ឯកឧត្តម **អុល រ៉ូ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៤ | មកឧត្តមមន្ត្រី ថ្នាក់លេខ៣ |
| ៨-ឯកឧត្តម **រឿង រដ្ឋា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៤ | មកឧត្តមមន្ត្រី ថ្នាក់លេខ៣ |
| ៩-លោក **នូ សុវណ្ណា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៤ | មកឧត្តមមន្ត្រី ថ្នាក់លេខ៣ |
| ១០-លោកស្រី **ស្រី សទ្ធា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៤ | មកឧត្តមមន្ត្រី ថ្នាក់លេខ៣ |
| ១១-លោកជំទាវ **សៅ សុគន្ធារី** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ៤ |
| ១២-ឯកឧត្តម **បាន់ វណ្ណី** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ៤ |
| ១៣-ឯកឧត្តម **ស សាម៉ីឌី** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ៤ |
| ១៤-លោកស្រី **ឆាយ គឹមសុទ្ធី** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ៤ |
| ១៥-លោក **ប្រាក់ ម៉ូវ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ៤ |
| ១៦-លោក **សយ រាសី** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ៤ |
| ១៧-លោក **ស្រេង ហុង** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ៤ |
| ១៨-ឯកឧត្តម **សួន វ៉ានី** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ៥ |
| ១៩-លោក **អ៊ុក សុភាព** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ៥ |
| ២០-លោកស្រី **អ៊ុក ទូច** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ៥ |
| ២១-លោក **ស៊ីន សុភីន** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ៥ |
| ២២-លោក **អ៊ុង ណារឿង** | ពីឧត្តមមន្ត្រី ថ្នាក់លេខ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ៥ |

